**តមកពីទំព័រទី១ ស**

ត្រូវក្រុមអ្នកតំណាងរាស្ត្រខ្មែរ, មន្ត្រីសង្គមស៊ីវិល និងប្រជាពលរដ្ឋខ្មែរ ជាអ្នករស់នៅ តាមព្រំដែននិយាយថាគឺផ្ទុះបញ្ចាំងការពិតទាំងអស់ ។

លោក*ម៉ៅ មុនីវណ្ណ*សមាជិកគណៈអចិន្ត្រៃយ៍ គណបក្សសមរង្ស៊ីជាអ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាមមានជំនឿ លើរបាយការណ៍នេះថា ជាការផ្ទុះបញ្ចាំងការពិត ហើយសបញ្ជាក់ដែរថា នៅក្នុងគណបក្សប្រជាជន មានអ្នកស្នេហាជាតិដែរ ។

លោក*ម៉ៅ មុនីវណ្ណ*បានមានប្រសាសន៍ថា "*ទោះបីជា យ៉ាងណាក៏ដោយ ខ្ញុំសង្កេតឃើញថា របាយការណ៍របស់ឯកឧត្តមកែ គឹមយ៉ានហ្នឹង គាត់ផ្ទុះបញ្ចាំងនូវទិដ្ឋភាពពិត ជាក់ស្តែង នៅតាមព្រំដែន រវាងខ្មែរ-យួន ។ នៅក្នុង គណបក្សប្រជាជនហ្នឹងមានអ្នកស្នេហាជាតិពិតប្រាកដច្រើនគ្នាណាស់ គ្រាន់តែនៅក្នុងកាលៈទេសៈអំណាច ប្រមូលផ្តុំទៅលើបុគ្គលម្នាក់ហ្នឹងឯង អ្នកដែលស្នេហាជាតិហ្នឹងគាត់ហាក់បីដូចជារារែកចិត្ត ។ ប៉ុន្តែក្នុងបេះដូងរបស់គាត់ នៅក្នុងអារម្មណ៍របស់គាត់ៗនៅតែគិតគូរពីបញ្ហាជាតិរបស់គាត់អ៊ីចឹង*" ។

លោក*ម៉ៅ មុនីវណ្ណ*បានមានប្រសាសន៍ទៀតថា លោក *កែ គឹមយ៉ាន* ក្នុងនាមគាត់ កាលជាអគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ, គាត់ធ្វើរបាយការណ៍ ជូនទៅនាយករដ្ឋមន្ត្រីតាមទិដ្ឋភាពជាក់ស្តែង ដែលគេ (យួន សៀម) រំលោភនៅលើដីខ្មែរមួយចំនួននេះ ក៏ធ្លាប់ត្រូវបានលោកចុះទៅដល់ចំណុចខ្លះដែលមាន នៅក្នុងរបាយការណ៍នេះដែរ ។ លោកបានបន្តទៀតទិដ្ឋភាពជាក់ស្តែង ដែលលោកបានចុះទៅដល់ព្រំដែននោះ ជាពិសេសព្រំដែន ជាប់ជាមួយនឹងប្រទេសយួន គឺយួនបានរំលោភចូលក្នុងដីខ្មែរមែន ។

លោក*ម៉ៅ មុនីវណ្ណ* បានបន្តថា ទិដ្ឋជាក់ស្តែង និងថ្មីៗបំផុតនេះ គឺនៅបង្គោលឡាក់ លេខ ១៨៥ដែលលោក*សម រង្ស៊ី* បានទៅដល់ផ្ទាល់ កាលពីថ្ងៃទី២៥ តុលា ២០០៩នោះ គឺអ្នកភូមិបានធ្វើរបាយការណ៍ ជូនលោក*សម រង្ស៊ី* ថា ការបោះបង្គោលព្រំដែននោះ មានសុទ្ធតែយួនគឺមានតែប៉ូលិសខ្មែរម្នាក់ប៉ុណ្ណោះទៅឈរមើលនោះ គឺអត់ឃើញមានគណៈកម្មការ ព្រំដែនខ្មែរណាម្នាក់ទេ ។ លោក*ម៉ៅ មុនីវណ្ណ* បានបញ្ជាក់ថា លោក *កែ គឹមយ៉ាន* ជាសមាជិក គណៈកម្មធិការកណ្តាលគណបក្សប្រជាជនដែរនោះ គាត់ប្រាកដជាប្រាប់ថ្នាក់ដឹកនាំ គណបក្សប្រជាជនច្រើនគ្នាបានដឹងហើយ ។

លោក*អ៊ុច ច័ន្ទឫទ្ធិ* សមាជិកសភាគណបក្សសិទ្ធិមនុស្ស នៅមណ្ឌលកណ្តាល មិនទាន់ចាត់ទុកថា របាយការណ៍នោះពិតឬមិនពិតទេប៉ុន្តែលោកបានឃើញរបាយការណ៍នោះមានរូបសញ្ញានិងត្រា របស់អគ្គមេបញ្ជាការនៃកងយោធពល ខេមរភូមិន្ទ និងឈ្មោះលោក*កែ គឹមយ៉ាន* ។ លោកបានបន្តថា របាយការណ៍នោះ មានបញ្ជាក់ទីតាំង ពេលវេលា បាតុភាពច្បាស់លាស់ ។

លោក*រ៉ុងឈុន* ប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ បានមានប្រសាសន៍ថា របាយការណ៍នោះគឺជាការពិត និងថាហេតុអ្វីបានជាគ្មានការឆ្លើយតបពីរដ្ឋាភិបាល ។ លោកបានថ្លែងថា "*របាយការណ៍របស់ឯកឧត្តម កែ គឹមយ៉ាន ដែលបានលើកឡើងហ្នឹង វាជាការពិតហើយ គ្រាន់ថារបាយការណ៍នោះតាំងពីឆ្នាំ១៩៩៩ រដ្ឋាភិបាលមិនបានចាត់វិធានការ ទៅលើរបាយការណ៍ដែលលោកកែគឹមយ៉ានបានដាក់ជូន ពីព្រោះមានពេលវេលាជាក់លាក់មានការបញ្ជាក់អំពីទំហំ នៃការបាត់បង់ ជាក់លាក់ បញ្ជាក់អំពីកងទ័ពយួនឈរជើង...ឃើញថា បញ្ហាក៏ជាក់លាក់ណាស់ ហើយរបាយការណ៍នេះ ក៏យកធ្វើជាផ្លូវការបាន ហើយរដ្ឋាភិបាល ត្រូវតែពិចារណា ដោះស្រាយពាក់ព័ន្ធជុំវិញបញ្ហាហ្នឹង ។ ខ្ញុំមានការសោកស្តាយ បន្ទាប់ពី របាយការណ៍នេះ ដាក់ជូនទៅដល់រាជរដ្ឋាភិបាល ប៉ុន្តែមិនបានឃើញមានវិធានការទប់ស្កាត់ ឬមានវិធានការអ្វី ទៅនឹងការរំលោភបូរណភាពទឹកដី មកលើកម្ពុជាពីសំណាក់ពីយួន*" ។

ប៉ុន្តែលោក*វ៉ា គឹមហុង* និងមន្ត្រីផ្លូវការរដ្ឋាភិបាល ជាច្រើនទៀតនិយាយថា គ្មានការបាត់បង់ទឹកដីខ្មែរ ទៅប្រទេសជិតខាងនោះទេ, ហើយការបោះបង្គោលព្រំដែនជាមួយប្រទេសវៀតណាមសព្វថ្ងៃក៏បានធ្វើទៅតាមផែនទី ដែលតម្កល់ទុកនៅឯអង្គការសហប្រជាជាតិដែរ ។

របាយការណ៍លោក*កែ គឹមយ៉ាន* កាលពីថ្ងៃទី១២ សីហា ឆ្នាំ១៩៩៩ មានចំនួន៨ទំព័រនិងទើបផ្លាយចេញ នៅពេលដែលមេដឹកនាំខ្មែរ កំពុងនិយាយថា កម្ពុជា គ្មានការបាត់បង់ ទឹកដីមួយមីលីម៉ែត្រនោះ, លោក*កែ គឹមយ៉ាន* បានសំណូមពរ ទៅលោក*ហ៊ុន សែន* ថា :

១-រាជរដ្ឋាភិបាល មានផែនការកសាង ហេដ្ឋារចនាសម្ព័ន្ធនៅតាមមូលដ្ឋាន ជាប់ព្រំដែន ដើម្បីគួបផ្សំការងារ ការពារប្រទេស និងអភិវឌ្ឍន៍ ប្រទេសជាតិ ។

២-ចំពោះបញ្ហាដោះមីននៅតាមបណ្តោយព្រំដែន ត្រូវមានការឯកភាព ជាមួយគណៈកម្មការព្រំដែន និងក្រសួងការពារជាតិ ដើម្បីធានាឱ្យបាន ទាំងផ្នែកបច្ចេកទេស និងទាំងផ្នែកសន្តិសុខជាតិ ។

៣-យកចិត្តទុកដាក់ អភិវឌ្ឍន៍ តំបន់ព្រំដែន ច្រើនជាងកន្លែងផ្សេងៗ ។

៤-រាជរដ្ឋាភិបាល ពង្រឹងសមត្ថភាព និងផ្តល់លទ្ធភាពគ្រប់គ្រាន់អោយគណៈកម្មការព្រំដែនជាតិ បំពេញកិច្ចការបានល្អ ។

៥-រាជរដ្ឋាភិបាល ចំណាយថវិកា ដើម្បីកសាងទីកន្លែង ចាំបាច់មួយចំនួន នៅតាមព្រំដែន (គំរោង កសាងលំអិត និងផ្ញើជូននៅពេលក្រោយ) ។

៦-រាជរដ្ឋាភិបាលមានគោលនយោបាយច្បាស់លាស់ ចំពោះកងកម្លាំងប្រដាប់អាវុធ និងប្រជាជន ដើម្បីលើកទឹកចិត្តដល់អ្នកដែលស្ម័គ្រចិត្ត ទៅរស់នៅតាមបណ្តោយព្រំដែន ។

៧-រាល់គំរោងការសាងសង់យុទ្ធសាស្ត្រសំខាន់ៗនៅតាមព្រំដែន ស្នើអោយមានការ រួមយោបល់ពិភាក្សា របស់អគ្គមេបញ្ជាការ ក្រសួងការពារជាតិ គណៈកម្មការព្រំដែនជាតិ ។

៨-ពង្រាយ កំលាំងយោធាព្រំដែន និងនគរបាល ទៅព្រំដែនជំនួសឱ្យកម្លាំងទ័ពស្រួច ។

៩-តាមព្រំដែន កន្លែងណាដែលភាគីទាំងសង្ខាង បានឯកភាពគ្នារួចត្រូវបោះបង្គោល ឱ្យហើយឆាប់ មិនត្រូវរង់ចាំរហូតដល់មានការឯកភាព ទាំងស្រុងទើបបោះបង្គោលនោះទេ ។

១០-ការពង្រឹងកងទ័ពអោយបានរឹងមាំត្រូវធ្វើជាចាំបាច់ មិនអាចមើលស្រាលសភាពការណ៍បានឡើយ ។

តាំងពីនោះមកដល់ពេលនេះ គេទើបឃើញកម្ពុជា ពង្រាយកម្លាំងនៅតាមព្រំដែនខាងលិច តែប៉ុណ្ណោះ ខណៈដែលសៀម លើកទ័ព ឈ្លានពានខ្មែរ ទាំងហ្វូង កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៨ ។ ប៉ុន្តែនៅថ្ងៃទី២៥ តុលា ២០០៩ លោក*សម រង្ស៊ី* ឃើញឆ្អាលព្រំដែនជាមួយយួននៅប៉ែកខាងកើតបែរជារដ្ឋាភិបាលលោក*ហ៊ុន សែន*ចាត់វិធានការប្តឹង ដកអភ័យឯកសិទ្ធិ តាមអ្វីដែលជាសំណើ របស់នាយករដ្ឋមន្ត្រីយួនទៅវិញ ៕

**តមកពីទំព័រទី១ ន**

ពីរប្រកាសដកឯកអគ្គរដ្ឋទូតរៀងៗខ្លួនមកប្រទេសរបស់ខ្លួនវិញ ជារឿងដែលកើតចេញពីបញ្ហាថ្មី នៃការតែងតាំងអតីតនាយករដ្ឋមន្ត្រីសៀម *ថាក់ស៊ីន ស៊ីណាវ៉ាត្រា* ឱ្យធ្វើជាទីប្រឹក្សានាយករដ្ឋមន្ត្រីកម្ពុជាលោក *ហ៊ុន សែន*និងទីប្រឹក្សាសេដ្ឋកិច្ចរដ្ឋាភិបាលភ្នំពេញនោះ បញ្ហានៅមិនទាន់បញ្ចប់បាននៅឡើយទេ។

ក្រុងបាងកកបង្ហាញនូវការក្តៅចិត្តយ៉ាងខ្លាំងដូចបញ្ជាក់ឱ្យដឹងតាមរយៈការប្រកាសលុបចោលជាឯកតោភាគីនូវសន្ធិសញ្ញាអនុស្សារណយោគយល់គ្នា រវាងក្រុងបាងកក និងក្រុងភ្នំពេញ ចុះហត្ថលេខានៅថ្ងៃទី ១៨ ខែមិថុនា ឆ្នាំ២០០១ស្តីពីការធ្វើអាជីវកម្មរុករកប្រេងឧស្ម័នធម្មជាតិក្រោមបាតសមុទ្រនៃតំបន់ដែលគេប្រើពាក្យថា តំបន់ត្រួតស៊ីគ្នា ជាកិច្ចព្រមព្រៀងចុះហត្ថលេខារវាងកម្ពុជាតំណាងដោយលោក*ហោ ណាំហុង* នៃរដ្ឋាភិបាលលោក *ហ៊ុន សែន*និងសមភាគីក្រុងបាងកកសម័យ *ថាក់ស៊ីន ស៊ីណាវ៉ាត្រា*នោះ ។ការលុបចោលរបស់ក្រុងបាងកកនេះ យ៉ាងណាក៏ដោយក៏បានដុតកំដៅមេដឹកនាំកម្ពុជាផងដែរ ហើយរបៀបជាការឆ្លើយឆ្លងសងសឹកក្នុងគំនុំចិត្តនយោបាយទៅវិញនោះ រដ្ឋាភិបាលលោក *ហ៊ុន សែន* ក៏បានសម្រេចកាលពីថ្ងៃសុក្រកន្លងទៅប្រកាសលុបចោលកិច្ចព្រមព្រៀងដែលកម្ពុជាចុះហត្ថលេខាជាមួយប្រទេសសៀម ក្នុងការខ្ចីលុយសៀមជាង៤១លានដុល្លារមកជួសជុល និងសាងសង់កំណាត់ផ្លូវជាតិមួយនៅភាគពាយព្យនៃប្រទេសកម្ពុជា។

កិច្ចព្រមព្រៀងនោះនិយាយអំពីរដ្ឋាភិបាលលោក*ហ៊ុន សែន* ខ្ចីបុលប្រទេសសៀមនូវលុយប្រមាណ១៤០០លានបាត ត្រូវជា៤១លានដុល្លារថាយកមកជួសជុលកំណាត់ផ្លូវជាតិលេខ ៦៨ ភ្ជាប់ពីស្រុកក្រឡាញ់ ក្នុងខេត្តសៀមរាប ឆ្លងទៅក្រុងសំរោងខេត្តឧត្តរមានជ័យបង្ហួសទៅដល់អូរស្មាច់នៃច្រកព្រំដែនអន្តរជាតិខ្មែរ ជាមួយសៀម។ ហើយការវិវឌ្ឍន៍ចុងក្រោយនោះត្រូវបានប្រកាសបកស្រាយដោយអ្នកនាំពាក្យនៃក្រសួងការបរទេសកម្ពុជា លើហេតុផលថា ការលុបចោលនោះ ពីព្រោះកម្ពុជាមានថវិកាខ្លួនឯងគ្រប់គ្រាន់ទៅហើយ ហើយដែលនាយករដ្ឋមន្ត្រីកម្ពុជាលោក *ហ៊ុនសែន*នឹងធ្វើពិធីបើកការដ្ឋានជួសជុលសាងសង់កំណាត់ផ្លូវនោះនៅថ្ងៃទី៥ ខែធ្នូ ខាងមុខ។

បើទោះបីជាដោយហេតុផលយ៉ាងណាក៏ដោយ ការសម្រេចចិត្តធ្វើឡើងក្នុងស្ថានភាពលើជម្លោះការទូតរវាងក្រុងបាងកកនិងក្រុងភ្នំពេញកាន់តែតានតឹងឡើងហើយដែលលោក *ហ៊ុន សែន*នាយករដ្ឋមន្ត្រីកម្ពុជាបានប្រកាសថា ជារឿងផ្ទាល់ខ្លួនរបស់គាត់ទល់នឹងនាយករដ្ឋមន្ត្រីសៀម *អាប់ភីស៊ីត វ៉ាចាជីវ៉ា* ដែលបញ្ហានេះក៏ក្លាយទៅជារឿងរបស់រដ្ឋាភិបាលតំណាងប្រទេសទាំងពីរ និងជាបញ្ហាបុគ្គលវិវឌ្ឍន៍មកជាបញ្ហាជាតិនោះ ពួកអ្នកសង្កេតការណ៍សម្គាល់ឃើញថាតំរិយាបទនេះហាក់បីដូចជាមានដំណើរបញ្ច្រាស់ស្រគីនៃកិច្ចប្រឹងប្រែងរកការបន្ធូរបន្ថយភាពតានតឹង។

នោះក៏ពីព្រោះតែនាយករដ្ឋមន្ត្រីកម្ពុជាខ្លួនឯងបានបញ្ជូនគណៈប្រតិភូជាន់ខ្ពស់នៃក្រសួងការពារជាតិ និងមេទ័ពសំខាន់ៗរបស់ប្រទេសដឹកនាំដោយលោក *ទៀ បាញ់* ទៅជួបសមភាគីសៀម *ប្រាវិត វង់សាវ៉ាន* នៃក្រសួងការពារជាតិសៀមនៅទីក្រុងបាងកកកាលពីថ្ងៃទី២៦-២៧ ខែវិច្ឆិកា ដើម្បីរកការបន្ធូរបន្ថយភាពតានតឹង។

ប៉ុន្តែមិនដឹងយ៉ាងម៉េច ក៏មានការប្រកាសលុបចោលនូវកិច្ចព្រមព្រៀងខ្ចីបុលប្រទេសសៀមនេះហើយដែលរឿងនេះសមាជិកសភានៃគណបក្សសមរង្ស៊ីសម្តែងកង្វល់បារម្ភថា ពុំគួរបង្កើតឱ្យមានបញ្ហាថ្មីក្នុងពេលដែលកំពុងមានការព្យាយាមរកវិធានការកាត់បន្ថយជម្លោះរវាងប្រទេសទាំងពីរជាពិសេសការដោះស្រាយបញ្ហា ទឹកដីព្រំដែនភាគខាងជើង នៃកម្ពុជានោះទេ។

លោក *យឹម សុវណ្ណ* សមាជិកសភាកម្ពុជាពីគណបក្សសមរង្ស៊ី និងក៏ជាអ្នកនាំពាក្យរបស់គណបក្សនេះផង បានមានប្រសាសន៍ថាកម្ពុជាពុំគួរធ្វើការសម្រេចចិត្តជាឯកតោភាគីនូវអ្វីៗដែលនាំឱ្យមានការល្អក់កករសៅហ្មងក្នុងទំនាក់ទំនងរវាងប្រទេសជិតខាងទាំងពីរ ដែលកំពុងតានតឹងនោះឡើយ។

លោក *យឹម សុវណ្ណ* បានថ្លែងយ៉ាងនេះថា "*មិនគួរធ្វើអ្វីដែលបង្ករឱ្យមានភាពតានតឹងទេនៅពេលកំពុងមានការចរចាដើម្បីនឹងដោះស្រាយបញ្ហាទឹកដីនៅតំបន់ប្រាសាទព្រះវិហារ*"។ លោកបានបន្តថា រដ្ឋាភិបាលជាពិសេសមេដឹកនាំនៃប្រទេសជិតខាងទាំងពីរនេះគួរតែចៀសវៀងនូវចំណុចទាំងឡាយណាដែលបង្កើតឱ្យមានភាពតានតឹងថែមទៀតនោះ។

ពួកអ្នកសង្កេតការណ៍និយាយថាបញ្ហាទឹកដីព្រំដែនរវាងប្រទេសទាំងពីរ មើលទៅមិនងាយនឹងដោះស្រាយបាននោះទេ ដោយហេតុផលច្រើនយ៉ាង។ គេលើកពីហេតុផលទី១នៅត្រង់ថា រដ្ឋាភិបាលលោក *ហ៊ុន សែន* មិនព្រមយកបញ្ហានេះទៅដាក់នៅអង្គការសហប្រជាជាតិពីព្រោះយើងដឹងហើយថា ពួកអ្នកកាន់អំណាច នៃប្រទេសសៀមនេះបានបង្ហាញឱ្យឃើញរួចមកហើយនូវចេតនាប្រើវិធីចរចាការទូតអូសបន្លាយពេលវេលាហាក់ដូចជាមិនចង់ឱ្យមានដំណោះស្រាយដោយយុត្តិធម៌ត្រឹមត្រូវនោះទេ។ ហើយលើសពីនេះទៅទៀតរដ្ឋាភិបាលលោក *ហ៊ុន សែន* នៃគណបក្សប្រជាជន ការបញ្ជាក់ជំហរដូចជាបដិសេធច្រានចោលនូវកិច្ចព្យាយាមជួយអន្តរាគមន៍របស់ប្រទេសឥណ្ឌូណេស៊ី សហប្រធាននៃកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសដែលមានកាតព្វកិច្ចធានាការគោរពអនុវត្តកិច្ចព្រមព្រៀងនេះដូច្នេះក៏ធានានូវការការពារបូរណភាពទឹកដីកម្ពុជានោះ រដ្ឋាភិបាលកម្ពុជា នៃលោក *ហ៊ុន សែន* បានបន្ទាបតម្លៃនៃកិច្ចព្រមព្រៀងនេះ ហើយទាំងមិនហ៊ានបោះជំហាន កុំថាឡើយដើរទៅមុខសៀម សូម្បីដើរទន្ទឹមនឹងសៀមក្នុងការបបួលលើកបញ្ហាទៅដាក់នៅវេទិកាពហុភាគីអន្តរជាតិតាមរយៈកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសក្តី ឬក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិក្តីនោះ។

ប្រទេសដែលមានឥទ្ធិពលធំៗមកលើកម្ពុជា ក៏ដូចជាប្រទេសដែលមានឥទ្ធិពលលើក្រុងបាងកកនោះ ដូចជាមិនចង់មានខ្លួនចូលរួមនៅក្នុងកិច្ចប្រឹងប្រែងបញ្ចប់បញ្ហារវាងប្រទេសជិតខាងទាំងពីរ កម្ពុជាសៀមឡើយ។ មានការលើកទឹកចិត្តឱ្យការព្យាយាមដោះស្រាយដោយការចរចាទ្វេភាគី។ ទោះជាយ៉ាងនេះក៏ដោយ សហរដ្ឋអាមេរិក ដែលជាហត្ថលេខីដ៏សំខាន់នៃកិច្ចព្រមព្រៀងក្រុងប៉ារីស និងមានឥទ្ធិពលលើរដ្ឋាភិបាលក្រុងបាងកកនោះ បានបញ្ជាក់នូវជំហររបស់ខ្លួនថាបញ្ហានេះថា បើបញ្ហានេះក្រុងភ្នំពេញ និងក្រុងបាងកកមិនអាចដោះស្រាយដោយវិធានការចរចាទ្វេភាគីនេះ គួរតែដោះស្រាយបញ្ហាក្នុងតំបន់អាស៊ាន។

ដំណោះស្រាយនេះក៏ពិបាកនឹងធ្វើឡើងទៀត ពីព្រោះសូម្បីតែប្រធានាធិបតីប្រទេសឥណ្ឌូណេស៊ី ជាប្រទេសដែលរួមជាមួយប្រទេសបារាំងជាសហប្រធាននៃកិច្ចព្រមព្រៀងក្រុងប៉ារីសឥណ្ឌូណេស៊ីបានបង្ហាញនូវឆន្ទៈចង់ជួយសម្រុះសម្រួលបញ្ហានោះ ក៏លោក *ហ៊ុន សែន* មេដឹកនាំកម្ពុជាបានច្រានចោលនិងងាកទៅនិយាយថា ខុសចិត្តយកការចរចាទ្វេភាគីវិញ។

គឺជំហរនេះ តាមការមើលឃើញរបស់គណៈកម្មការព្រំដែនកម្ពុជា មូលដ្ឋាននៅទីក្រុងប៉ារីស ដែលមានលោក *ស៊ាន ប៉េងសែ* អតីតអ្នកគូសវាសផែនទីព្រំដែនខ្មែរនោះ ជំរើសផ្លូវដើរដោយរដ្ឋាភិបាលលោក *ហ៊ុន សែន* នឹងមិនអាចដោះស្រាយ ឬក៏បើដោះចេញ ក៏ប្រើរយៈពេលយូរណាស់៕

**តមកពីទំព័រទី១ គ**

ចំនួន១០ម៉ឺនដុល្លារ ទៅអ្នកស្រី *យ៉ា សុខនីម* ដែលរងគ្រោះដោយការវាយប្រហារទឹកអាស៊ីតដ៏ទារុណ កាលពីឆ្នាំមុន។

ជនដែលមានទោស ទាំង៦នាក់នេះ ដែលកំពុងតែរស់នៅក្រៅការឃុំឃាំងនៅឡើយ គឺជាអ្នកដំបូងគេបង្អស់ នៃក្រុមជនប្រើប្រាស់ទឹកអាស៊ីត ធ្វើជាអាវុធ វាយប្រហារទៅលើជនស្លូតត្រង់នៅកម្ពុជា ។ អ្នកទាំង៥នាក់នោះ គឺលោកស្រី*ជា រដ្ឋា* អាយុ៤៣ឆាំជាមេខ្លោងនៃបទឧក្រិដ្ឋ, និងជនដៃដល់ ស្រោចទឹកអាស៊ីតផ្ទាល់ដៃឈ្មោះ*មាស ម៉ៅ* អាយុ៤០ឆ្នាំ និងអ្នកបើកយានជំនិះ ឈ្មោះ*សៀក ចាន់ឌី* ត្រូវកាត់អោយជាប់ពន្ធនាគារចំនួន១៨ឆ្នាំ ។ ឯអ្នកសមគំនិតឈ្មោះ*អ៊ា ពុទ្ធា* អាយុ៣៣ឆ្នាំ, *សាំង នុត* អាយុ២៩ឆ្នាំ និង *សៀក សុផល* អាយុ២៥ឆ្នាំ និងឈ្មោះ*ចាន់ តារា* ត្រូវបានកាត់ទោសអោយជាប់ពន្ធនាគារ ១៥ឆ្នាំពីបទសមគំនិត។

លោក*សេង ស៊ីវុត្ថា* ចៅក្រមដែលកាត់ក្តី នៅក្នុងរឿងនេះបាននិយាយថាតុលាការសាលាឧទ្ធរណ៍មានភស្តុតាងគ្រប់គ្រាន់សម្រាប់ដំណើរការនៃការកាត់ទោសនេះនៅខណៈពេលដែលលោក*ណាច ទ្រី* មេធាវីការពារក្តីឱ្យឧក្រិដ្ឋជន*ជា រដ្ឋា* និងបក្ខពួកនិយាយថា ការសំរេចក្តីនេះគ្មានភស្តុតាងគ្រប់គ្រាន់ ។

ក្រោយពី តុលាការសាលាដំបូងរាជធានីភ្នំពេញ លុបចោលការចោទប្រកាន់ទៅលើលោកស្រី*ជា រដ្ឋា* និងបក្ខពួករួចមក, អ្នកស្រី*យ៉ា សុខនីម* និងសមាជិកគ្រួសារដែលភ័យខ្លាច បានធ្វើសន្និសីទកាសែតមួយ ដោយបង្ហាញខ្សែអាត់សម្លេង របស់លោកស្រី*ជា រដ្ឋា* ផងដែរ ដែលខ្សែអាត់នោះ លោកស្រី*ជា រដ្ឋា* បានព្រមានសម្លាប់ ទៅលើអ្នកស្រី*យ៉ា សុខនីម* ។

ប៉ុន្តែមហាជនខ្មែរ ចង់ឃើញថា តុលាការខ្មែរ ថ្កោលទោស និងផ្តន្ទាទោស ទៅលើអ្នកស្រី*យួន សុផល* អតីតភរិយារបស់មន្ត្រីជាន់ខ្ពស់នៅទីស្តីការគណៈ

**តទៅទំព័រទី៣ គ**

តមកពីទំព័រទី១ ខ

នេះ និយាយអះអាងអំពីរឿងនេះ។ តាមប្រភពនោះ ពួកឈ្មួញត្រូវរ៉ូវគ្នាជាមួយមន្ត្រីអាជ្ញាធរមានឥទ្ធិពល ហើយបានប្រើទឹកលុយជួយប្រជារាស្ត្រក្រីក្រឱ្យចូលព្រៃដើម្បីនឹងកាប់ឈើប្រណីត ជាពិសេសប្រភេទក្រញូងក្នុងសកម្មភាពល្មើសច្បាប់ ទាំងល្មើសបំពាននឹងបទបញ្ជានាយករដ្ឋមន្ត្រីក្លាយទៅជាសាបជាងទឹកមាត់ ចំពោះការកាប់ និងជួញដូរឈើខុសច្បាប់នោះ។

ពួកអ្នកភូមិត្រូវបានគេស្រង់សម្តីនិយាយអំពីការដែលឈើប្រណីតប្រភេទគ្រញូង មួយម៉ែត្រគូបលក់ក្នុងតម្លៃ២៥០០ដុល្លារនោះឈ្មួញអាចធ្វើសកម្មភាពបានដោយការបង់លុយទៅឱ្យមន្ត្រីប៉ូលិស យោធា និងប៉េអឹមសមត្ថកិច្ច ក៏ដូចជាបង់ទៅឱ្យឆ្មាំឧទ្យាន ដើម្បីនឹងអាចឱ្យពួកគេដឹកឈើចេញពីព្រៃ ចុះតាមទូកតូចៗ កាត់តាមស្ទឹងឆ្លងចូលស្រុកបានលុង និងបន្តដឹកពេលយប់ៗទៅកាន់តំបន់ព្រំដែន ដែលនៅទីនោះមានឈ្មួញយួនចាំទទួលទិញ។

សកម្មភាពជួញដូរឈើប្រណិតខុសច្បាប់ប្រព្រឹត្តដោយឈ្មួញដែលមានទំនាក់ទំនងចែកប្រយោជន៍ជាមួយមន្ត្រីសមត្ថកិច្ចក្នុងជួរប្រដាប់អាវុធនៅខេត្តរតនគិរី ត្រូវបានគេរាយការណ៍ថា មានកើតឡើងទាំងនៅក្នុងស្រុកអណ្តូងមាស ស្រុកអូរយ៉ាដាវ រហូតដល់ស្រុកតាវែង ហើយអាជ្ញាធរមូលដ្ឋានដូចជាមិនបានយកចិត្តទុកដាក់ក្នុងការបង្ក្រាបនោះទេ។

មន្ត្រីស្រុកបរកែវមួយរូបសុំមិនបញ្ចេញឈ្មោះបាននិយាយប្រាប់វិទ្យុអាស៊ីសេរីអំពីការដែលក្រុមហ៊ុនឈ្មួញបានប្រើឱ្យកម្មករយករណាម៉ាស៊ីនទៅអារច្រៀកឈើគ្រញូងដល់ក្នុងព្រៃ ហើយដែលសកម្មភាពនេះមានទាំងដូចអ្វីដែលមន្ត្រីស្រុកជាប្រភពនោះនិយាយថា "*នៅព្រៃគេលក់ដូរឈើ ហើយនៅស្រុកក៏គេលក់ដូរឈើ* "។

គាត់បាននិយាយអំពីការដែលអ្នកកាប់ឈើក្នុងព្រៃត្រូវគេជួលឱ្យប្រើរណាម៉ាស៊ីនរហូតដល់សកម្មភាពបង្ក្រាបក្លាយទៅជាបែបអនាធិបតេយ្យទៅវិញ ដោយពាក្យតាមការថ្លែងរបស់គាត់ថា "*ប៉ូលិសចាប់ទាហាន ទាហានចាប់ប៉ូលិស វាក្លាយទៅជាសង្គ្រាមបែបអនាធិបតេយ្យ* "។

សកម្មភាពកាប់ឈើប្រណិតខុសច្បាប់មានដូចជានៅអូរតាបូកជាដើម ហើយក៏កើតមាននៅក្នុងស្រុកផ្សេងៗផងដែរ។អូរតាបូកដែលមានទីតាំងប្រមាណ១៥គីឡូម៉ែត្រពីស្រុកអណ្តូងមាស នៃខេត្តរតនគិរី អ្នកស្រុកត្រូវគេជួលឱ្យចូលកាប់ឈើប្រណីត។ ហើយឈើអស់ទាំងនោះត្រូវបានគេដឹកជញ្ជូនដាក់មាត់ស្ទឹង និងដឹកតាមទូកកាណូតតូចៗ តាមអូរ ពីស្រុកតាវែង ទៅដល់ស្រុកវ៉ឺនសៃ។

សកម្មភាពនៃការកើតមានការកាប់ឈើប្រណិតខុសច្បាប់ និងការជួញដូរនេះ មន្ត្រីអាជ្ញាធរស្រុកក៏ដឹងដែរដូចដែលប្រភពនិយាយថា "*ស្រុកក៏ដឹង ហើយ ទាហាន ប៉ូលិស ក៏គេដឹង ប៉ុន្តែគេមិនចាប់* "។

ក៏មានរបាយការណ៍អំពីការដែលឃើញមានសកម្មភាពបង្ក្រាបទប់ស្កាត់តិចតួចដែរ ដូចករណីដែលកើតមានក្នុងខែសីហា ឆ្នាំ២០០៣ ដែលនៅពេលនោះមានការចាប់រថយន្តពីរគ្រឿង ដែលបានដឹកឈើប្រណីតចេញពីឧទ្យាន។

រឿងនេះប្រធានក្រុមប្រឹក្សាស្រុកតាវែងបានទទួលស្គាល់អំពីការកើតមានការកាប់ឈើប្រណិត និងការជួញដូរឈើប្រណិតខុសច្បាប់នោះដែរ។ ប្រធានក្រុមប្រឹក្សានេះ នៃខេត្តរតនគិរីបាននិយាយអំពីរឿងនេះថា "*មានការប្រជុំប្រចាំខែក៏មានដាក់ផែនការ។ ខាងស្រុកក៏ទទួលស្គាល់ការមានការកាប់ឈើប្រណិត និងជួញដូរឈើប្រណិតខុសច្បាប់*។

មន្ត្រីខេត្តរតនគិរី ជាប្រភពមួយទៀតដែលបានប្រាប់វិទ្យុអាស៊ីសេរីនោះបាននិយាយអំពីការកើតមានសកម្មភាពដឹកជញ្ជូនឈើ ប្រណិតខុសច្បាប់តាមរយៈរថយន្ត ជាពិសេសនៅពេលយប់ៗពី៣ទៅ៥គ្រឿង ហើយពេលខ្លះមានលក្ខណៈគគ្រឹកគគ្រេង ឆ្លងទៅដល់តំបន់ព្រំដែន ដែលនៅក្នុងទឹកដីយួនចំងាយ១គីឡូម៉ែត្រពីព្រំដែន ក៏មានឃ្លាំងយួនសម្រាប់ទិញឈើប្រណិតពីកម្ពុជាតម្កល់ទុក។ ប្រភពនោះនិយាយថានៅទីនោះមានឃ្លាំងស្តុកឈើប្រណិតពីកម្ពុជាដល់ទៅ៣ ឬ៤កន្លែង ហើយដែលមានបរិមាណឈើខ្ទង់រាប់ពាន់ម៉ែត្រគូប ដែលគាត់អះអាងអំពីការមានរូបថត និងរូបវីដេអូបញ្ជាក់ទៀតផង។

ហើយករណីមួយនោះឈើប្រណិតប្រមាណជាង១រយម៉ែត្រគូប ត្រូវបានគេរកឃើញលាក់ទុកនៅក្នុងព្រៃដីចំការរបស់អតីតចៅហ្វាយខេត្តរតនគិរី*ខាំឃឿន* ក្នុងស្រុកអូរយ៉ាដាវជាប់ព្រំដែនយួន ជាផ្នែកនៃគម្រោងការរបស់ពួកក្រុមហ៊ុនឈ្មួញឃុបឃិតជាមួយមន្ត្រីខិលខូចក្នុងការដឹកយកទៅលក់ឱ្យឈ្មួញយួនដែលចាំទិញនៅឯច្រកព្រំដែនកម្ពុជាវៀតណាមចុងកំណាត់ផ្លូវជាតិលេខ៧៨។

គេពុំដឹងថា តើហេតុអ្វីអាជ្ញាធរថ្នាក់ខេត្ត រហូតដល់អាជ្ញាធរថ្នាក់ជាតិជាពិសេសទាំងនាយករដ្ឋមន្ត្រីកម្ពុជាលោក *ហ៊ុន សែន* ផងមិនអាចចាត់វិធានការឱ្យមានប្រសិទ្ធិភាពដើម្បីទប់ស្កាត់ ឬបង្ក្រាបនូវបទល្មើសកាប់ឈើប្រណិត និងជួញដូរឈើប្រណិតពីក្នុងព្រៃកម្ពុជាបន្តទៅលក់ឱ្យឈ្មួញយួនបែបនោះទេ?ហើយជាការគួរឱ្យមានការកត់សម្គាល់ក្នុងសម្លេងឡើងឆ្ងល់ដែរនោះគឺសកម្មភាពកាប់ឈើប្រណិតបានប្រព្រឹត្ត និងកំពុងប្រព្រឹត្តទៅក្នុងព្រៃជាយឧទ្យានជាតិវីរៈជ័យ ហើយដែលកំពុងបន្តរាលដាលទៅក្នុងឧទ្យានជាតិដែលការពារដោយព្រះរាជក្រឹត្យ និងច្បាប់របស់ប្រទេស ប៉ុន្តែពុំឃើញសមត្ថកិច្ចរបស់រដ្ឋាភិបាលថ្នាក់ណាមួយអនុវត្តវិធានការបំបាត់ឱ្យបាននូវបញ្ហាឧក្រិដ្ឋកម្មព្រៃឈើនេះទេ។

លោកនាយករដ្ឋមន្ត្រី *ហ៊ុន សែន* ខ្លួនឯង កាលក្នុងអំឡុងឆ្នាំ២០០១បានប្រកាសថាក្រោមការដឹកនាំរបស់គាត់ គាត់មានការសោកស្តាយ ហើយគាត់ទទួលស្គាល់ និងទទួលខុសត្រូវក្នុងការដែលកើតមាននូវការកាប់បំផ្លាញឈើហុបកម្ពុជាអស់រាប់លានម៉ែត្រគូប (Sic)។ នាយករដ្ឋមន្ត្រីបានទាំងប្រកាសសន្យាជាសាធារណៈទៀតថា បើគាត់ត្រួតត្រារដ្ឋាភិបាលហើយមិនអាចបង្ក្រាបទប់ស្កាត់បទល្មើសនៃការកាប់ឈើ និងដឹកជញ្ជូនឈើខុសច្បាប់នៅក្រោយថ្ងៃទី១ ខែមករា ឆ្នាំ២០០២ទេនោះ គាត់នាយករដ្ឋមន្ត្រី *ហ៊ុន សែន* នឹងសុខចិត្តលាលែងពីតំណែង។

យ៉ាងនេះក៏ដោយមកដល់ពេលនេះ សកម្មភាពនៃការកាប់ដឹកជញ្ជូនឈើក្នុងជំនួញខុសច្បាប់នៅតែបន្តកើតមានដោយពុំមានការទប់ស្កាត់ឡើយ៕



តមកពីទំព័រទី១ ៩

តែបង្ខិតបង្ខំ ឱ្យរុះរើលំនៅដ្ឋានស្របច្បាប់របស់ខ្លួនចេញ ដើម្បីយកដីនោះ ប្រគល់ឱ្យក្រុមហ៊ុនយួន ។

ព្រះអង្គ មានព្រះជន្ម ៨១ ព្រះវស្សា ដែលកំពុងតែគង់នៅក្នុងវត្តមួយរាជធានីភ្នំពេញបានមានសង្ឃដីកា ប្រាប់ *ខ្មែរម្ចាស់ស្រុក* ថា ព្រះអង្គបានស្តាប់វិទ្យុថា មានប្រជាពលរដ្ឋខ្មែរ ជាច្រើន ដែលក្នុងនោះ មានទាំងព្រះសង្ឃផង កំពុងតែមានទុក្ខដោយសារតែសមត្ថកិច្ច កម្លាំងយោធា ឡោមព័ទ្ធ មិនអោយពួកគាត់អាចចេញមកខាងក្រៅបាន ដើម្បីទទួលយក ចំណីអាហារ របស់សប្បុរសជន និងពីអង្គការ ក្រៅរដ្ឋាភិបាល ដែលមានចិត្តសន្តោស ប្រោសប្រណីនោះទេ ។

ប្រជាពលរដ្ឋ នៅឃុំក្រយាស្រុកសន្ទុក ខេត្តកំពង់ធំ ជាងមួយពាន់គ្រួសារ ភាគច្រើន ជាជនពិការដោយសារសង្គ្រាមរស់នៅតំបន់នោះស្របច្បាប់ ច្រើនឆ្នាំមកហើយៗទើបតែនៅពេលឥឡូវនេះត្រូវបានសមត្ថកិច្ចប្រើអំពើហិង្សា បង្ខំឱ្យអ្នកភូមិចាកចេញ ដើម្បីយកដីនោះ ប្រគល់ឱ្យក្រុមហ៊ុនរបស់យួន ឈ្មោះតាន់បៀន គ្រោងនឹងបង្កើតចំការកៅស៊ូ លើផ្ទៃដីទំហំ ៨ពាន់ហិកតា នៅភូមិគ្រយា ឃុំគ្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ដែលជាដីសម្បទានពីរាជរដ្ឋាភិបាលកាលពីឆ្នាំ២០០៧ ។ប៉ុន្តែអ្នកភូមិប្រហែលមួយពាន់គ្រួសារនិយាយថា ដីនៅតំបន់នោះ ជារបស់ពួកគាត់ ដែលទទួលបានកម្មសិទ្ធិស្របច្បាប់ ក្នុងមួយគ្រួសារ 30m X 500m នៅលើផ្ទៃដីទំហំសរុប ចំនួនមួយម៉ឺនហិកតា ។

គិតត្រឹមថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩កន្លងទៅនេះ សមត្ថកិច្ចខេត្តកំពង់ធំ ចាប់បាន អ្នកភូមិ ចំនួន៨នាក់ហើយ នៅក្នុងគំរោងចាប់ខ្លួនចំនួន២០នាក់ដែលចោទថាបានបំផ្លាញទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ។ ព្រឹត្តិការណ៍ដែលឈានដល់ មានការប្រើអំពើហិង្សា បានកើតឡើងកាលពីថ្ងៃទី១៦ វិច្ឆិកា ២០០៩ គឺនៅពេលដែលអ្នកភូមិ ការពារដីកម្មសិទ្ធិរបស់ពួកគាត់ ដែលធ្វើឱ្យសន្តិសុខក្រុមហ៊ុន ប្រើអំពើហិង្សា ហើយបញ្ចេះកំហឹងឱ្យអ្នកភូមិ ដុតបំផ្លាញ ទ្រព្យសម្បត្តិក្រុមហ៊ុន ដែលក្នុងនោះមានរថយន្ត និងម៉ូតូ១០គ្រឿងផងដែរ ។

អង្គការសិទ្ធិមនុស្សធំៗចំនួន២នៅកម្ពុជា គឺអង្គការ ការពារសិទ្ធិមនុស្សលីកាដូនិងអាដហុកបានធ្វើសកម្មភាព យ៉ាងសកម្ម ដើម្បីអោយមានការ សម្របសម្រួលគ្នា រវាងក្រុមហ៊ុន ជាមួយអ្នកភូមិ ជាពិសេសអោយសមត្ថកិច្ចបញ្ឈប់សកម្មភាពជាបន្ទាន់ ក្នុងការតាមចាប់ អ្នកភូមិ ។ ប៉ុន្តែសមត្ថកិច្ច នៅតែបន្តយាមកាម យ៉ាងតឹងតែងបំផុត។

អាជ្ញាធរខេត្តបាននិយាយជាចំហ ដោយមិនលាក់លៀមថា ការប្រើអំពើហិង្សាបណ្តេញប្រជាពលរដ្ឋ នៅឃុំគ្រយានោះគឺគ្មានអ្វីខុស ពីអាជ្ញាធរ ទីក្រុងភ្នំពេញ ធ្លាប់បណ្តេញប្រជាពលរដ្ឋពីលំនៅដ្ឋាន អោយទៅរស់នៅជាយក្រុងនោះទេដែលការអះអានេះ បានធ្វើឱ្យព្រះតេជគុណ*សឹង តុងលី* មានសង្ឃដីកាថា ព្រះអង្គធ្លាប់ធ្វើទាហាននៅសម័យមុនៗ និងជាកូនចៅមេទ័ព*ដាប ឈួន* ផង មិនដែលធ្វើបាប ប្រជាពលរដ្ឋ បាញ់ប្រជាពលរដ្ឋខ្មែរ ដូចជាទាហាន នៅក្នុងសម័យ លោក*ហ៊ុន សែន* នេះទេ ។ ព្រះអង្គបានបន្តថាបើអ្នកភូមិនោះ ជាឪពុកម្តាយ ជាបងប្អូនសមត្ថកិច្ច ដែលគេប្រើឱ្យធ្វើបាបអ្នកភូមិនោះ តើអស់លោកមានអារម្មណ៍ យ៉ាងណាដែរទៅ ?

ព្រះតេជគុណ *សឹង តុងលី* បានបន្តទៀតថា ទាហានលោក *ហ៊ុន សែន* សាហាវណាស់ គឺធ្វើបាបរាស្ត្រខ្លួនឯង ដើម្បីយកដីឱ្យក្រុមហ៊ុនយួន, ហើយថា បើអស់លោកគោរពយួនយ៉ាងហ្នឹង នៅថ្ងៃណាមួយ យួននឹង យកក្បាលអស់លោក ដាំតែអុងដូចបុព្វបុរសខ្មែរ កាលពីជំនាន់មុនដែរហើយ ។

គួរបញ្ជាក់ថា អ្នកភូមិ ដែលភាគច្រើន ជាជនពិការ ដោយសារសង្គ្រាមនេះបានរស់នៅលើដីនោះជាច្រើនឆ្នាំមកហើយនិងមានការអនុញ្ញាត របស់ក្រសួងមហាផ្ទៃផងដែរ ដែលពួកគាត់បានដាំដំណាំដូង ស្វាយ ខ្នុរ ដំឡូងមី និងដំណាំហូបផ្លែ ជាច្រើនទៀត ដែលធ្វើឱ្យពួកគាត់មិនអាចបោះបង់ចោលបាន ។

ការដែលអ្នកភូមិប្រកាន់នូវជំហរមិនព្រមរុះរើ លំនៅដ្ឋានចាកចេញនេះហើយ ទើបធ្វើឱ្យអាជ្ញាធរ អនុវត្តវិធានការអំពើហិង្សាបណ្តេញអ្នកភូមិ យ៉ាងកំរោលបួនជ្រុង ហើយសព្វថ្ងៃប្រជាពលរដ្ឋ កំពុងត្រូវបាន អាជ្ញាធរឡោមព័ទ្ធ និងចង់បណ្តេញអ្នកភូមិនៅតំបន់នោះ តាមរយៈនៃការទប់ស្កាត់មិននាំយកអាហារទៅលក់ដូរ ឬហាមមិនឱ្យសប្បុរសជននាំយកជំនួយស្បៀង ទៅជួយដល់អ្នកទាំងនោះ។

អ្នកភូមិ និងអ្នកដែលឃើញហេតុការណ៍ផ្ទាល់ភ្នែកខ្លះ បាននិយាយថា ទាហានខ្មែរខ្លាំងតែជាមួយពលរដ្ឋខ្មែរស្លូតត្រង់និងអត់ធ្មត់ ជាមួយទាហាន ឈ្លានពានសៀមនៅតាមព្រំដែន គួរឱ្យអស់សំណើច ។

ទោះយ៉ាងណា គេមិនរំពឹងថាព្រះតេជគុណ*សឹង តុងលី*នឹងនឹងអាចចូលជួបអ្នកភូមិនោះបានទេ, ហើយព្រះអង្គក៏នៅមិនទាន់កំណត់ពេលច្បាស់លាស់ថានឹងនិមន្តទៅនៅថ្ងៃណាដែរ ៕

តមកពីទំព័រទី២ គ

រដ្ឋមន្ត្រីដែរ ដែលបានវាយប្រហារ ទៅលើតារាខារ៉ាអូខេនៅចំពោះមុខហ្វូងមនុស្ស កាលពីឆ្នាំមុន, ហើយជនល្មើសនិងបក្ខពួកនៅតែគ្មានទោស ទោះបីជាករណីឧក្រិដ្ឋជ័យឃ្នងនេះត្រូវបានជនបរទេស ចងក្រង ជាខ្សែភាពយន្ត រំលឹកព្រឹត្តិការណ៍នោះ ដែលហាក់ដូចជានៅថ្មីៗក៏ដោយ ។ ការមិនផ្តន្ទាទោសទៅលើលោកស្រី*យួន សុផល* និងបក្ខពួកនេះបានធ្វើឱ្យជនឧក្រិដ្ឋផ្សេងទៀត ដែលអាងខ្នង អ្នកមានអំណាច មិនញញើត នឹងការប្រព្រឹត្តបទល្មើសឡើយ ។

លោកស្រី*យួន សុផល* និងបក្ខពួក បានធ្វើទារុណកម្មទៅលើនាង*តាត ម៉ារីណា* ហើយក៏ស្រោចទឹកអាស៊ីត ទៅលើជនរងគ្រោះជាចំហ នៅចំពោះមុខមហាជនដែលបទល្មើសនេះគួរតែទទួលទោស ធ្ងន់ធ្ងរជាងអ្នកស្រី*ជា រដ្ឋា* ផងនោះ។

បើទោះបីជាតុលាការសាលាឧទ្ធរណ៍ បានសំរេចផ្តន្ទាទោសលោកស្រី*ជា រដ្ឋា* និងបក្ខពួកយ៉ាងសមហេតុផល និងក៏មានការស្វាគមន៍ ពីគ្រប់មជ្ឈដ្ឋានក៏ដោយ ក៏សមត្ថកិច្ចត្រូវតែ ធ្វើការតាមចាប់ខ្លួន ជនល្មើស*ជា រដ្ឋា* និងបក្ខពួកឱ្យមកទទួលទោសតាមផ្លូវច្បាប់។

លោក*អ៊ួង វិបុល* ស្វាមីជនរងគ្រោះ*យ៉ា សុខនីម* បានរីករាយ នឹងព័ត៌មាននេះ ប៉ុន្តែជនរងគ្រោះ និងសមាជិកគ្រួសារជាច្រើនរូបទៀត នៅតែមានការភ័យខ្លាចនៅឡើយ ដោយសារតែជនល្មើស ស្ថិតនៅក្រៅឃុំនៅឡើយនោះ។

កាលពីថ្ងៃទី៣១ សីហា ឆ្នាំ ២០០៩ ចៅក្រមពរូប ដែលក្នុងនោះ មានឈ្មោះ*សែម សក្តិកូណា* កូនស្រីលោកស្រី*លី វួចឡេង* អតីតប្រធានតុលាការសាលាឧទ្ធរណ៍ បានសំរេចលុបចោលការចោទប្រកាន់ ទៅលើលោកស្រី*ជា រដ្ឋា* និងបក្ខពួក ដែលធ្វើឱ្យ មានការរិះគន់ធ្ងន់ៗពីគ្រប់មជ្ឈដ្ឋាន ដែលក្នុងនោះក៏រួមទាំង មន្ត្រីប៉ូលិសផងដែរ ដែលបានស្វែងរកចាប់ខ្លួន ជនល្មើសយ៉ាងលំបាកនោះ ។

សមត្ថកិច្ចចាប់បានជនល្មើស ដែលវាយប្រហារដោយទឹកអាស៊ីតផ្ទាល់ឈ្មោះ*មាស ម៉ៅ* និងអ្នកដែលបើកយានជំនិះ ឈ្មោះ*សៀក ចាន់ឌី* ។ ប៉ុន្តែតុលាការសាលាដំបូង កាលពីថ្ងៃទី៣១ ក៏បានបញ្ជាឱ្យដោះលែង ជនល្មើសទាំង២នាក់នេះដែលធ្វើឱ្យលោកស្រី*យ៉ា សុខនីម* និងសមាជិកគ្រួសារ ជាពិសេស គឺកញ្ញា*អ៊ុន សុខលីដា* បានគេចខ្លួនទៅក្រៅប្រទេស ។

អ្នកស្រី*យ៉ា សុខនីម* ដែលជាជនរងគ្រោះ ដោយការវាយប្រហារទឹកអាស៊ីត បំផ្លាញរាងកាយលោកស្រីនោះបានបំបែកស្នេហាភេទដូចគ្នា រវាងលោកស្រី*ជា រដ្ឋា* ពីក្មួយស្រីបវរកញ្ញាទេសចរណ៍*អ៊ុន សុខលីដា* ដែលធ្វើឱ្យអ្នកស្រី ជាគោលដៅ នៃការវាយប្រហារ ដោយទឹកអាស៊ីត របស់ក្រុមមនុស្ស លោកស្រី*ជា រដ្ឋា* ។

ទោះយ៉ាងណា ការបំបែកសំណុំរឿងដែលស្មុគស្មាញ និងឆ្លងកាត់ឧបសគ្គជាច្រើន ទើបតុលាការសាលាឧទ្ធរណ៍ សំរេចក្តីទៅតាមវិជ្ជាជីវៈនោះ ក៏នៅមិនទាន់ទទួលបានស្វាគមន៍ ឱ្យកក់ក្តៅពីប្រជាពលរដ្ឋខ្មែរ នៅឡើយទេ ដោយសារតែ ក្រុមជនល្មើស នៅតែស្ថិតនៅក្រៅឃុំនៅឡើយ, ហើយរឿងដែលសំខាន់នោះ គឺតុលាការ ត្រូវតែមានវិធានការជាបន្តទៀត ទៅលើជនល្មើស ដែលវាយប្រហារដោយទឹកអាស៊ីត ទៅលើតារាខារ៉ាអូខេ*តាត ម៉ារីណា* ពីព្រោះមេខ្លោងជនល្មើស ក៏ត្រូវបានគេស្គាល់យ៉ាងច្បាស់ដែរហើយដែរ។

អ្នកវិភាគនានា បាននិយាយថានេះ នេះគឺជាចំណុចវិជ្ជមានរបស់តុលាការខ្មែរ ដែលទទួលរងនូវការរិះគន់ពីគ្រប់មជ្ឈដ្ឋានថា មិនឯករាជ្យ និងពុករលួយនោះ ។ ការសំរេចដាក់ទោសជនឧក្រិដ្ឋ*ជា រដ្ឋា* និងបក្ខពួកនេះ គឺបន្ទាប់ពីតុលាការសាលាដំបូង និងសាលាឧទ្ធរណ៍ កាលពីពេលថ្មីៗនេះ បានកាត់អោយមានទោស ទៅលើស្រីទំនើង *ខែ ដារ៉ា*, ហៅ*ហ្គិច* ឬហៅ*កែវរតនៈ* ឱ្យជាប់ពន្ធនាគារ ចំនួន ១៨ខែ និងពិន័យជាប្រាក់ចំនួនមួយលានរៀលពីបទប្រើប្រាស់អាវុធខុសច្បាប់ ៕

ក្រុមហ៊ុនភាពយន្ត
ជនបទ
មានទទួលបញ្ចាំង
ខ្សែភាពយន្តខ្នាតធំ
ក្នុងពិធីផ្សេងៗ
មានពន្លឺច្បាស់
និងមានលក់ម៉ាស៊ីន
បញ្ចាំងខ្សែភាពយន្ត
ទំនាក់ទំនងតាមទូរស័ព្ទ
012 66 44 67
015 66 44 67

តមកពីទំព័រទី១ ម

លើដីស្រែរបស់ពួកគាត់នោះ នៅអាមេរិកខាងជើងជនជាតិខ្មែរនិងអាមេរិកាំង កាណាដា បាននាំគ្នាតវ៉ាដូចជាតាមរយៈបាតុកម្មអហិង្សា នាពេលប៉ុន្មានម៉ោងខាងមុខនេះទៀត នៅមុខស្ថានទូតកម្ពុជាប្រចាំរដ្ឋធានីវ៉ាស៊ីនតោន ក៏ដូចជានៅមុខសភាជាតិ នៃប្រទេសកាណាដា។ ពួកអ្នករៀបចំបាតុកម្មគម្រោងនឹងធ្វើចាប់ពីម៉ោង១១ថ្ងៃត្រង់ ដល់ម៉ោង៥រសៀលនៃថ្ងៃទី២៨ ខែវិច្ឆិកា ម៉ោងនៅអាមេរិក និងកាណាដា ហើយត្រូវគ្នានឹងព្រឹកថ្ងៃអាទិត្យម៉ោងនៅកម្ពុជា ទាំងអស់គ្នានិយាយរំលឹកឡើងថា កាណាដា និងសហរដ្ឋអាមេរិកគឺជាហត្ថលេខីនៃកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ២៣ តុលា ១៩៩១ដូច្នេះក៏ត្រូវធានានូវការគោរពសិទ្ធិមនុស្សដែលកំពុងជាបញ្ហាដ៏ធ្ងន់ធ្ងរនៅកម្ពុជាបច្ចុប្បន្ន។

អ្នករៀបចំបាតុកម្មម្នាក់បាននិយាយនៅទីក្រុងម៉ុងរ៉េអាល់នៃប្រទេសកាណាដាថា ការធ្វើបាតុកម្មនេះដើម្បីទាមទារឱ្យមានការវិលត្រឡប់មកនូវប្រជាធិតេយ្យ និងច្បាប់នៅកម្ពុជាវិញ។

គាត់បានបន្តទៀតថាគោលបំណងដ៏ធំនៃបាតុកម្មនេះនៅកាណាដា ក៏ដូចជានៅទីក្រុងវ៉ាស៊ីនតោននោះ គឺដើម្បី "*ឱ្យសភាជាតិ ជាសភាពេញច្បាប់។ យើងធ្វើនេះមិនមែនដើម្បីគ្រាន់តែសម្តែងមតិប៉ុណ្ណោះទេ។ នៅក្នុងប្រទេសដែលមានសេរីភាពលទ្ធិប្រជាធិបតេយ្យនោះ គេគោរពច្បាប់គោរពសិទ្ធិមនុស្ស*"។

អ្នករៀបចំបាតុកម្មមួយរូបសម្រាប់គម្រោងមុខរដ្ឋសភាកាណាដា នាទីក្រុងអូតាវ៉ាបាននិយាយថា "*ប្រទេសកាណាដាក្តី សហរដ្ឋអាមេរិកក្តី រដ្ឋាភិបាលប្រទេសទាំងពីរនេះ ដែលជាហត្ថលេខី ចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្រុងប៉ារីស២៣ តុលា ១៩៩១នោះ ត្រូវធានាឱ្យមានការគោរពអនុវត្តសន្ធិសញ្ញានេះ*"។លោកបាននិយាយដល់ស្ថានភាពនៃបញ្ហាសិទ្ធិមនុស្សនៅកម្ពុជាដ៏អាក្រក់បច្ចុប្បន្នតាមរយៈការដាក់គំនាបគាបសង្កត់ដកព្យួរអភ័យឯកសិទ្ធិសភារបស់តំណាងរាស្ត្រលោក *សម រង្ស៊ី* មេគណបក្សប្រឆាំងដ៏ធំនៅកម្ពុជា។

ចូលរួមនៅក្នុងសកម្មភាពគោលដៅតែមួយ ប៉ុន្តែនៅទីក្រុងផ្សេងគ្នានារដ្ឋធានីវ៉ាស៊ីនតោន នៃសហរដ្ឋអាមេរិកនោះ លោក *អ៊ុន សុខុម*ដែលជាអតីតសមាជិកគណៈកម្មការនាយកគណបក្សសមរង្ស៊ី បាននិយាយអត្ថាធិប្បាយរិះគន់ដល់ការសមាជិកសភាគណបក្សប្រជាជនកាន់អំណាចនៅកម្ពុជាបានប្រជុំជាសម្ងាត់កាលពីថ្ងៃទី១៦ ខែវិច្ឆិកាដកព្យួរអភ័យឯកសិទ្ធិសភារបស់លោក *សម រង្ស៊ី* ព្រោះតែបញ្ហាពាក់ព័ន្ធនឹងរឿងព្រំដែន។

ដោយហេតុនេះ លោក *អ៊ុន សុខុម*បានថ្លែងថាចលនាប្រឆាំងថ្កោលទោសក៏បានធ្វើដូចជាបាតុកម្មក្នុងឆ្នាំ២០០៥ ប្រឆាំងនឹងការចុះហត្ថលេខាលើសន្ធិសញ្ញាដោយលោកនាយករដ្ឋមន្ត្រីកម្ពុជា *ហ៊ុន សែន* និងមេដឹកនាំយួនលើបញ្ហាព្រំដែន។

លោក *អ៊ុន សុខុម* បាននិយាយអំពីការដែលលោកធ្លាប់មានបទពិសោធន៍ដើរកំប៉ាល់អន្តរជាតិយូរឆ្នាំដូច្នេះគេកត់សម្គាល់យ៉ាងច្បាស់ សូម្បីតែនៅលើសមុទ្រ កំណត់ដឹងថា ត្រង់ណាជាព្រំដែនសមុទ្រ នៃប្រទេសនីមួយៗ ដោយគេប្រើប្រាស់ឧបករណ៍អេឡិចត្រូនិចទំនើបៗ GPS ។ដូច្នេះលោកធ្វើការជជែកវែកញែកទៅនឹងអ្វីជាសេចក្តីថ្លែងរបស់លោក *វ៉ា គីមហុង* អំពីការបោះបង្គោលព្រំដែន ជាពិសេសនៅឃុំសំរោងស្រុកចន្ទ្រាខេត្តស្វាយរៀងដែលបានក្លាយទៅជាប្រធានបទដ៏សំខាន់រហូតដល់មានការប្រឆាំងបែបនយោបាយទៅលើលោក *សម រង្ស៊ី* មេដឹកនាំគណបក្សជំទាស់ដ៏ធំនោះ។

ក្នុងរឿងលោក *សម រង្ស៊ី* នេះ លោក *ពីទីម៉ា* បាននិយាយថា នោះជាតឹកតាងបញ្ជាក់ឱ្យឃើញនូវការធ្លាក់ចុះនៃលទ្ធិប្រជាធិបតេយ្យរបស់ប្រទេសកម្ពុជា។ លោកបានថ្លែងថា "*បញ្ហាទាក់ទងដោយផ្ទាល់ទៅនឹងការធ្លាក់ចុះនៃលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសជាតិយើង ដែលយើងកំពុងដើរទៅរករបបផ្តាច់ការ* "។

លោក *ពីទីម៉ា* បានបញ្ជាក់បន្ថែមទៀតថា "*អ្វីៗដែលរដ្ឋាភិបាលកម្ពុជាបានដកព្យួរអភ័យឯកសិទ្ធិសភារបស់លោក សម រង្ស៊ី តាមរយៈសភាជាតិនោះ គឺជាការគំរាមច្បាស់ណាស់ មិនមែនតែគំរាមចំពោះលោកសម រង្ស៊ី ប្រធានគណបក្សប្រឆាំងដ៏ធំនោះទេ គឺក៏ជាការគំរាមដល់សមាជិកសភាទាំងអស់* "។ លោកបានហៅថា នោះគឺជាការមិនគោរពសិទ្ធិសេរីភាពរបស់ប្រជារាស្ត្រ ដែលជាអ្នកបានបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ទាំងលោក *សម រង្ស៊ី* នោះ។

មិនមែនតែជនជាតិខ្មែរនោះទេសូម្បីតែអ្នកនយោបាយជាន់ខ្ពស់របស់សហរដ្ឋអាមេរិក គឺតំណាងរាស្ត្រដ៏មានឥទ្ធិពលច្រើននាក់បានចូលរួមបញ្ចេញប្រតិកម្មនៅក្នុងរឿងនេះ។ សមាជិកសភាសហរដ្ឋអាមេរិកដ៏មានឥទ្ធិពលពីររូប គឺលោក *អេតរ៉យ* និងលោក *គ្រីស ស្មិត* បានថ្លែងរិះគន់ដល់វិធានការអនុវត្តដោយរដ្ឋាភិបាល និងសភាជាតិកម្ពុជា ដែលនៅក្រោមអំណាចត្រួតត្រារបស់គណបក្សប្រជាជនក្នុងការដកព្យួរអភ័យឯកសិទ្ធិសភារបស់លោក*សម រង្ស៊ី*នោះថា គឺជាការគំរាមដល់ដំណើរការលទ្ធិប្រជាធិបតេយ្យក្នុងប្រទេសកម្ពុជានោះ។

លោកសមាជិកសភាសហរដ្ឋអាមេរិក *គ្រីស ស្មិត* បានពិពណ៌នា ករណីនៃការដកព្យួរអភ័យឯកសិទ្ធិរបស់លោក*សម រង្ស៊ី* ថា ជាការបង្ហាញថា រដ្ឋាភិបាលកាន់អំណាចនៅកម្ពុជាកំពុងព្យាយាមបំបាត់សម្លេងគណបក្សប្រឆាំង ពោលគឺគណបក្សសមរង្ស៊ី។

ហើយទាន់ទិននឹងករណីនៃការព្យួរអភ័យឯកសិទ្ធិសភារបស់លោក *សម រង្ស៊ី* ក៏ដូចជាសមាជិកសភាគណបក្សប្រឆាំងពីររូបទៀត លោកស្រី *មូរ សុខហួរ* និងលោក *ហូរ វ៉ាន់* ក្នុងអំឡុងរយៈពេលកន្លះឆ្នាំចុងក្រោយនេះ លោក *គ្រីស ស្មិត* ក៏បានរំលឹកឡើងទៅដល់ការដែលសមាជិកសភាសហរដ្ឋអាមេរិកដ៏មានឥទ្ធិពល៤រូប ជាមិត្តភក្តិជិតស្និទ្ធរបស់លោកដែលបានស្រុះស្រួលគ្នាធ្វើសេចក្តីព្រាងលេខ៨២០ ថ្កោលទោសការរំលោភសិទ្ធិមនុស្សនៅកម្ពុជា ក៏ដូចជាអំពើពុករលួយនិងការជួញដូរមនុស្សនៅក្រោមការត្រួតត្រារបស់រដ្ឋាភិបាល *ហ៊ុន សែន*។

លោក*ស្មិត* បានមានប្រសាសន៍អំពីការដែលសមាជិកសភាសហរដ្ឋអាមេរិកដ៏មានឥទ្ធិពលពីររូប ជាមិត្តិភក្ត្ររបស់លោករួមគ្នាធ្វើសេចក្តីសម្រេចលេខ៨២នោះ។ លោក *គ្រីស ស្មិត* បានអធិប្បាយថា"*សេចក្តីព្រាងច្បាប់នោះនិយាយថ្កោលទោសការរំលោភសិទ្ធិមនុស្ស និងការកើតមានអំពើពុករលួយនៅក្នុងប្រទេសកម្ពុជា។ ខ្ញុំមានការព្រួយបារម្ភអំពីបញ្ហាជួញដូរមនុស្សនៅក្នុងប្រទេសនេះ ជាពិសេសការជួញដូរកុមារ* "។

សមាជិកសភាសហរដ្ឋអាមេរិករូបនេះបាននិយាយអំពីរឿងនេះថា ជាបញ្ហាដ៏ធ្ងន់ធ្ងរដែលមនុស្សត្រូវគេទិញដូរហើយដែលរដ្ឋាភិបាលនៅកម្ពុជាគួរណាស់តែបំបាត់ចោលនូវទោសកម្មបែបទំនើបនេះ។

ចំពោះបាតុកម្មនៅរដ្ឋធានីវ៉ាស៊ីនតោន សហរដ្ឋអាមេរិកក៏ដូចជានៅប្រទេសកាណាដាថ្លែងប្រឆាំង និងថ្កោលទោសចំណាត់ការនៅកម្ពុជាក្នុងការដកព្យួរអភ័យឯកសិទ្ធិសភារបស់លោក *សម រង្ស៊ី* នេះ មន្ត្រីអ្នកនាំពាក្យ នៃទីស្តីការគណៈរដ្ឋមន្ត្រីរបស់រដ្ឋាភិបាលលោក *ហ៊ុន សែន* បានរិះគន់បាតុកម្មអហិង្សានៅណាដា និងសហរដ្ឋអាមេរិកនោះ។

លោក *ផៃ ស៊ីផាន* អ្នកនាំពាក្យនៃទីស្តីការគណៈរដ្ឋមន្ត្រីរបស់រដ្ឋាភិបាលក្រុងភ្នំពេញបាននិយាយថា ថ្វីបើបាតុកម្មអហិង្សាធ្វើឡើងនៅកាណាដានិងសហរដ្ឋអាមេរិកជុំវិញបញ្ហារបស់លោក *សម រង្ស៊ី* ជាសទ្ធិរបស់ខ្មែរនៅក្រៅប្រទេសក៏ដោយ ក៏តាមការថ្លែងរបស់លោក *ផៃ ស៊ីផាន* នោះថា បាតុកម្មនេះប្រឆាំងនឹងនីតិរដ្ឋនៅក្នុងស្រុកខ្មែរ។

លោក *ផៃ ស៊ីផាន* បាននិយាយរំលឹកដល់ករណីដែលលោក *សម រង្ស៊ី* បានចេញមុខឈឺឆ្អាលតាមការតវ៉ារបស់ប្រជារាស្ត្រម្ចាស់ដីស្រែនៅតំបន់ជាយដែនលើរឿងនៃការបោះបង្គោលព្រំដែន ធ្វើឡើងដោយគណៈកម្មាធិការព្រំដែននៃប្រទេសជិតខាតទាំងពីរកម្ពុជា-វៀតណាមនៅកណ្តាលដីស្រែរបស់ប្រជាកសិករខ្មែរ។ រឿងនោះលោក *ផៃ ស៊ីផាន* បានអធិប្បាយថាជាសកម្មភាពមិនគប្បីរបស់លោក *សម រង្ស៊ី* ទៅវិញ បើទោះបីប្រជារាស្ត្រខ្មែរម្ចាស់ដីស្រែបាននិយាយថា ពួកគាត់បានប្រឹងតវ៉ាដល់រដ្ឋាភិបាលលោក *ហ៊ុន សែន* ឱ្យជួយដោះស្រាយការពារជីវរបស់ពួកគាត់ ប៉ុន្តែរដ្ឋាភិបាលមិនបានជួយអ្វីឡើយរយៈ១៦ខែ ដូច្នេះពួកគាត់ក៏បានប្តឹងរកអន្តរាគមន៍ពីលោក *សម រង្ស៊ី*ប្រធាននៃគណបក្សប្រឆាំងដ៏ធំនៅកម្ពុជាវិញនោះ។

ការដកព្យួរអភ័យឯកសិទ្ធិសភារបស់លោក *សម រង្ស៊ី* ធ្វើឡើងដោយការប្រជុំជាបន្ទាន់នៃសមាជិកសភាគណបក្សប្រជាជនកាលពីថ្ងៃទី១៦ ខែវិច្ឆិកា នោះជាវិធានការដែលបានកើតមាននៅបន្តពីអាជ្ញាធរស្រុកចន្ទ្រា ខេត្តស្វាយរៀង បានប្តឹងទៅតុលាការ ដោយបានសុំឱ្យក្រសួងយុត្តិធម៌ នៃរដ្ឋាភិបាលលោក *ហ៊ុន សែន* រុញឱ្យសភាជាតិដកព្យួរអភ័យឯកសិទ្ធិសភារបស់លោក ជាពិសេសការដកនោះធ្វើឡើងនៅក្រោយពេលដែលនាយករដ្ឋមន្ត្រីយួន *ង្វៀន តាន់ឌុង* បានសម្តែងកំហឹងចំពោះការដែលលោក *សម រង្ស៊ី* និងប្រជារាស្ត្រខ្មែរម្ចាស់ដីស្រែដកបង្គោលតម្រុយចេញពីដីប្រជារាស្ត្រខ្មែរ។

លោក *សម រង្ស៊ី* ពេលនេះកំពុងបន្តបំពេញការងារក្នុងបេសកកម្មនៅទ្វីបអឺរ៉ុប ដើម្បីនឹងរកអន្តរាគមន៍ពីសភាអឺរ៉ុបក៏ដូចជាសភាអន្តរជាតិនៅទីក្រុងសឺណែវ ចំពោះបញ្ហានៃការដកព្យួរអភ័យឯកសិទ្ធិសភារបស់លោក ដោយសមាជិកសភានៃគណបក្សប្រជាជន ។លោកបានអធិប្បាយថា សភាអឺរ៉ុបបានសម្តែងចំណាប់អារម្មណ៍ ហើយក៏បានមានប្រតិកម្មជំរាបលោកក្នុងការរិះគន់អ្វីដែលជាការប្រព្រឹត្តដោយសមាជិកសភាគណបក្សប្រជាជនដកព្យួរអភ័យឯកសិទ្ធិសភារបស់លោកដោយសារតែរឿង លោក *សម រង្ស៊ី* បានបំពេញតួនាទីជាតំណាងរាស្ត្រ ហើយចូលរួមជាមួយប្រជារាស្ត្រដកបង្គោលព្រំដែនសីម៉ាដែលគេបានយកមកដោតដាំលើដីប្រជារាស្ត្រខ្មែរនៅតំបន់ជាយដែន ស្រុកចន្ទ្រា ខេត្តស្វាយរៀងនោះ៕

តមកពីទំព័រទី១ ក

កសិករខ្លួនឯងបាន។ ហើយច្បាស់ណាស់ថា ប្រទេសជិតខាងទាំងយួន ទាំងសៀម ដែលមានឈ្មោះនាំអង្ករចេញលក់លើទីផ្សារពិភពលោកជាប់លំដាប់ទី១ទីមួយប្រទេសសៀម និងលំដាប់ទី២ប្រទេសវៀតណាមនោះ មួយចំណែកក៏ដោយសារពួកគេបានស្រូវនាំចេញពីកម្ពុជាជាញើសឈាមរបស់កសិករខ្មែរសម្រាប់ការបង្កើនតួលេខនៃការនាំចេញរបស់ប្រទេសទាំងពីរឱ្យបានល្បីឈ្មោះនៅលើពិភពលោកផង ជាពិសេសកើបរកបានប្រាក់ចំណេញមួយឆ្នាំៗរាប់រយលានដុល្លារពីញើសឈាមរបស់កសិករខ្មែរដោយប្រយោលផង។

រឿងហ្នឹងគេគួរតែស្តីបន្ទោសចំពោះរបៀបចាត់ចែងគ្រប់គ្រងប្រទេសដោយរដ្ឋាភិបាល នៃលោក ហ៊ុន សែន ដែលថ្វីបើកាន់អំណាចជាង៣០ឆ្នាំនៅកម្ពុជាក៏នៅតែមិនអាចដោះស្រាយបញ្ហានេះបាន ហើយធ្វើឱ្យមានឪកាសចន្លោះប្រហោងសម្រាប់ពួកឈ្មួញឡើងពីប្រទេសយួន និងពីប្រទេសសៀមមកប្រមូលទិញស្រូវពីកសិករខ្មែរដោយតម្លៃថោកៗ ដើម្បីនឹងដាក់ផ្លាកសម្រាប់នាំចេញទៅទីផ្សារអន្តរជាតិដោយតម្លៃខ្ពស់នោះ។ ឥឡូវនេះតាមប្រភពអ្នករកស៊ីខាងជួញដូរស្រូវឆ្លងដែនទៅភាគខាងលិចរបស់កម្ពុជា មួយថ្ងៃៗស្រូវខ្មែរត្រូវគេនាំចេញក្នុងបរិមាណ៣០តោនទៅប្រទេសសៀម បើទោះបីជាមានការបិទព្រំដែន ហើយដែលនៅទីនោះ ស្រូវខ្មែរមួយគីឡូក្រោមឈ្មួញសៀមឱ្យតម្លៃតែ ១១បាត ប្រមាណ១១០០រៀលក្នុងពេលដែលឈ្មួញសៀមទិញស្រូវពីកសិករសៀមក្នុងតម្លៃដល់ទៅ១៣បាត ឬ១៣០០រៀលក្នុងមួយគីឡូ គឺថា គេឱ្យតម្លៃស្រូវកសិករគេខ្ពស់ លើសតម្លៃស្រូវកសិករខ្មែរ។ នេះមិនមែនមកពីគុណភាពស្រូវកសិករខ្មែរអន់ជាងស្រូវកសិករសៀមនោះទេ ប៉ុន្តែមកពីរដ្ឋាភិបាល និងមេដឹកនាំប្រទេសគេយកចិត្តទុកដាក់ខ្លាំងក្នុងការជួយប្រជាកសិករគេជាងមេដឹកនាំកម្ពុជាមិនអាចជួយកសិកររបស់ខ្លួនឯងបាន ព្រោះតែមិនមានការធានារកទីផ្សារដោយរដ្ឋាភិបាលកម្ពុជានោះ ប្រជាកសិករត្រូវបង្ខំចិត្តបញ្ជូនស្រូវរបស់ពួកគាត់ទៅលក់ឱ្យឈ្មួញដែលនាំឆ្លងដែនទៅកាន់ប្រទេសជិតខាងនោះ។

គ្រាន់តែចំណុចដ៏តូចមួយនៃការដែលឈ្មួញសៀមទិញស្រូវកសិករសៀមដោយតម្លៃ១៣បាតក្នុងមួយគីឡូក្រាម ហើយទិញស្រូវពីកសិករខ្មែរឱ្យតម្លៃតែ១១បាតក្នុងមួយគីឡូក្រាមនោះ ប៉ុណ្ណេះក៏គ្រប់គ្រាន់ឱ្យយល់បានដែរថា មានកត្តាពីរសម្រាប់ការរៀនសូត្រ។ ទី១នោះគឺរដ្ឋាភិបាល និងអ្នកគ្រប់គ្រងប្រទេសសៀមយកចិត្តទុកដាក់ជួយដល់កសិករគេ និងឱ្យតម្លៃលើពលកម្មរបស់កសិករគេ ជាងគិតគូរជួយដល់កសិករខ្មែរ ថ្វីបើគេត្រូវការកសិផលជាញើសឈាមរបស់ប្រជារាស្ត្រខ្មែរសម្រាប់បំពេញផែនការនៃការនាំចេញរបស់ពួកគេ ឬក៏ផែនការនៃតម្រូវការក្នុងស្រុករបស់ពួកគេក៏ដោយនោះ។ ហើយទី២នោះ ក៏វាជួយឱ្យដឹងដែរថា រដ្ឋាភិបាលកាន់អំណាចនៅកម្ពុជា ឬនិយាយឱ្យចំរដ្ឋាភិបាលដែលមាន លោក ហ៊ុន សែន ជានាយករដ្ឋមន្ត្រីនោះ ពុំបានជួយគិតគូរអ្វីក្នុងការដោះស្រាយបញ្ហា ដើម្បីនឹងលើកតម្លៃស្រូវរបស់កសិករខ្មែរ ឬក៏ការធានារកទីផ្សារសម្រាប់កសិផលស្រូវអង្កររបស់ប្រជារាស្ត្រខ្មែរខ្លួនឯងនោះដែរទេ។

និយាយអំពីផលស្រូវនេះ គេនៅចាំបានថា កាលដើមរដូវចំរូតឆ្នាំ២០០៨-២០០៩ គ្រាន់តែប្រជាកសិករខ្មែរចាប់ផ្តើមច្រូតស្រូវ ខ្លះមិនទាន់ទាំងបានជញ្ជូនមកដាក់ជម្រុកតាមផ្ទះរៀងៗខ្លួនផងនោះច្រកទ្វារព្រំដែនក៏ត្រូវគេបើកចំហរក្រោមលេសនៃរបស់ដែលហៅថា សេដ្ឋកិច្ចទីផ្សារសេរីបើកឱ្យក្រុមហ៊ុនឈ្មួញយួន ក៏ដូចជាឈ្មួញសៀមជញ្ជូនគ្នាមកប្រមូលទិញដោយចំហរនូវស្រូវកសិករខ្មែរដល់ស្រែ ឬជម្រុកផ្ទះដឹកចុះតាមផ្លូវគោក ជាពិសេសតាមផ្លូវទឹកគគ្រឹកគគ្រេងចេញពីកម្ពុជា។ គ្រានោះនាយករដ្ឋមន្ត្រីកម្ពុជាលោក ហ៊ុន សែន បានប្រកាសដោយមោទនភាពថា ស្រូវខ្មែរបានទិន្នផលដល់ទៅ៧លានតោនសម្រាប់ឆ្នាំនោះ ហើយសល់នូវស្រូវសម្រាប់ការនាំចេញដល់ទៅជាង២លានតោន។ គាត់បាននិយាយថា នោះគឺជាដំណឹងល្អរបស់ប្រជារាស្ត្រខ្មែរដែលធ្វើស្រែបានផលស្រូវ។ ប៉ុន្តែមិនបានប៉ុន្មានផង ក៏ស្រាប់តែមានវិបត្តិស្បៀងនៅកម្ពុជាកើតឡើងភ្លាមៗ រហូតដល់ធនាគារពភិវឌ្ឍន៍អាស៊ីបានប្រញាប់អនុវត្តគម្រោងជួយសង្គ្រោះដល់ស្បៀងស្រូវអង្ករជូនប្រជារាស្ត្រខ្មែរក្រីក្រនៅតំបន់ជុំវិញបឹងទន្លេសាបដែលជួបប្រទះនូវវិបត្តិខ្វះស្បៀង ដោយសារតែបញ្ហាស្បៀងឡើងថ្លៃជាផលវិបាកនៃនយោបាយបើកទ្វារចំហរព្រំដែនឱ្យឈ្មួញយួននិងឈ្មួញសៀមចូលមកប្រមូលទិញស្រូវពីកសិករខ្មែរនោះ។

សម្រាប់រដូវចំរូតឆ្នាំនេះ ដែលកសិករ ក៏កំពុងចាប់ផ្តើមប្រមូលផលបណ្តើរៗនោះតើកសិករខ្មែរនឹងជួបប្រទះនូវវាសនាដូចមុនជាផលវិបាកនៃកង្វះសមត្ថភាពដឹកនាំគ្រប់គ្រងផ្នែកពាណិជ្ជកម្មផ្នែកសេដ្ឋកិច្ច និងផ្នែកអ្វីៗរបស់រដ្ឋាភិបាលទៀតឬទេ បើក្រុមហ៊ុនស្រូវនៅកម្ពុជានិយាយអំពីការដែលគេអាចទិញស្រូវស្តុកទុកនៅប្រទេសកម្ពុជាបានតែ២០ ទៅ៣០ភាគរយ ហើយស្រូវកសិករខ្មែរច្រើនដល់៧០ភាគរយត្រូវបានឈ្មួញពីប្រទេសយួននិងប្រទេសសៀមចូលមកទិញដឹកជញ្ជូនទៅនោះ ? គេនៅពុំទាន់ដឹងថា តើនឹងមានបញ្ហាកើតឡើងនោះទៀតឡើយ ថ្វីបើមានការប្រមើលប៉ាន់ប្រមាណដោយពួកអ្នកជួញដូរស្រូវនៅស្រុកខ្មែរថា ស្រូវសើមមួយតោនគេឱ្យតម្លៃ១០៥០០០០រៀល ក្នុងពេលដែលស្រូវស្ងួតមួយតោនលក់តម្លៃ១៣០០០០០រៀលនោះ ។ហើយអ្វីគួរឱ្យកត់សម្គាល់គឺប្រធានសមាគមម៉ាស៊ីនស្រូវនៅកម្ពុជា ក៏ទទួលស្គាល់ថាឈ្មួញទិញស្រូវប្រជាកសិករខ្មែរក្នុងស្រុក ក៏ដូចជាស្រូវកសិករខ្មែរលក់ចេញទៅក្រៅស្រុក ក៏ត្រូវគេឱ្យតម្លៃថោកជាងតម្លៃស្រូវនៅលើទីផ្សារពិភពលោក។ បរិមាណខុសគ្នានៃតម្លៃស្រូវកសិករខ្មែរអាចពន្យល់បានថា នោះហើយជាការបញ្ជាក់ថាកសិករខ្មែរត្រូវគេចំរាញ់អាជីវកម្មប្រមូលផលចំណេញ ជាពិសេសដោយប្រទេសជិតខាងទាំងពីរយួន និងសៀម ហើយជាការប្រាប់ថា រដ្ឋាភិបាលខ្មែរពុំមានសមត្ថភាពនឹងជួយប្រជាកសិករខ្មែរកុំឱ្យក្លាយទៅជាការធ្វើអាជីវកម្មពីបណ្តាឈ្មួញនៃប្រទេសជិតខាងនោះ៕